ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...៦៣៤.....សនខប

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៦..

## សេចក្តីណែនាំ

## ស្តីពីការកំណត់មុខសញ្ញាចំណាយ និងនីតិវិធីចំណាយ
## កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌
## សេវាសុខាភិបាលចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល

ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការអនុវត្តប្រកាសអន្តរក្រសួងលេខ ៣០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៦ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៃក្រសួងសុខាភិបាល សូមធ្វើការណែនាំបន្ថែមលើចំណុចមួយចំនួនដូចខាងក្រោម÷

១. មុខសញ្ញាចំណាយលម្អិត

- ចំណាយចាំបាច់សម្រាប់ការងាររដ្ឋបាល រួមមានជាអាទិ៍÷
  - ការទិញសម្ភារតូចតាចសម្រាប់ការងារសង្គ្រោះបន្ទាន់
  - ការថតចម្លងឯកសារ
  - ការថែទាំ និងជួសជុលតូចតាចចាំបាច់ភ្លាមៗ (ដូចជា: សម្ភារបរិក្ខារបច្ចេកទេស សម្ភារបរិក្ខារពេទ្យ)
  - ការថែទាំអនាម័យ និងបរិស្ថាន
- ចំណាយសម្រាប់សង្គ្រោះបន្ទាន់ និងចាំបាច់ (ប្រេងរថយន្តគិលានសង្គ្រោះ)
- ចំណាយទិញឱសថ និងបរិក្ខារតូចតាចដែលចាំបាច់ (ដូចជា: សំឡី កុំប្រេស ជេស...)
- ការផ្សព្វផ្សាយ និងវិធានលើការលើកកម្ពស់គុណភាពសេវាសុខាភិបាលផ្សេងទៀត

២. រាល់ប្រតិបត្តិការចំណាយតាមមុខសញ្ញាខាងលើត្រូវមានឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវជាអាទិ៍រួមមាន ប័ណ្ណស្នើសុំចំណាយ ប័ណ្ណចំណាយ វិក្កយបត្រចំណាយ និងឯកសារសំអាងដទៃទៀត ជាមូលដ្ឋានសម្រាប់កិច្ចបញ្ជិកា របាយការណ៍ និងសវនកម្មក្រោយចំណាយ។

៣. ប្រធានមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព មានសិទ្ធិចាត់ចែងរក្សាសាច់ប្រាក់ក្នុងបេឡាសម្រាប់ការងារចាំបាច់តាមតម្រូវការ ដោយទទួលខុសត្រូវទាំងស្រុងចំពោះហានិភ័យនានាជាយថាហេតុ។

៤. ប្រធានមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវទទួលខុសត្រូវគ្រប់គ្រងប្រើប្រាស់ថវិកាចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ឱ្យចំទិសដៅ តម្លាភាព គណនេយ្យភាព និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ប្រធានអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស ប្រធានមន្ទីរពេទ្យបង្អែក និងប្រធានមណ្ឌលសុខភាព ត្រូវអនុវត្តតាមសេចក្តីណែនាំខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

<u>កន្លែងទទួល:</u>

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- រតនាគាររាជធានី-ខេត្ត
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត (ដើម្បីអនុវត្ត និងផ្សព្វផ្សាយបន្ត)
- ឯកសារ-កាលប្បវត្តិ